# Xx

**xanthophylle** *n.f.* សង់តូភីល(ជាតិពណ៌លឿងនៅក្នុងស្លឹកឈើ ត្របកផ្កា និងផ្លែឈើ)

**xanthoprotéique** *adj.* សង់តូប្រូតេអ៊ិច។ réaction ~ ប្រតិកម្មសង់តូប្រូតេអ៊ិច។

**xénon** *n.m.* សេណុង. *Lampe au xénon.* អធិប្បាយៈ សេណុង មាននិមិត្តសញ្ញា Xe ជាឧស្ម័នគ្មានក្លិនគ្មានពណ៌ មានលេខអាតូមិច 54 ។ វាជា *ឧស្ម័នកំរ* (Fr. gaz rare) ស្ថិតនៅក្នុងក្រុម១៨ នៃតារាងខួបគីមី។ សេណុងត្រូវបានគេរកឃើញនៅឆ្នាំ១៨៩៨ ដោយអ្នកវិទ្យាសាស្ត្រប្រ៊ីតានិច ស័រ វីល្លៀមរ៉ែមសេ (Sir William Ramsay) និង ម៉ូរីស ត្រាវ៉ែស(Morris Travers)។ ពីដំបូងគេជឿថាវា *គ្មានប្រតិកម្មគីមីជាមួយធាតុផ្សេងទៀត* តែនៅឆ្នាំ១៩៦២គេបានបង្កើតសមាសធាតុនៃសេណុងជាច្រើន។ សេណុងត្រូវបានគេយកទៅប្រើនៅក្នុងឧបករណ៍បំភ្លឺដូចជា *ទូបផូតូក្រាភិចល្បឿនលឿន* (High-speed photographic tubes)។ សេណុងមាននៅក្នុងខ្យល់នៅក្នុងបរិមាណដ៏តិចតួច។ ក្នុងឧស្សាហកម្ម គេផលិតសេណុងភាគច្រើនដោយបំនិតយកពីខ្យល់។ សេណុងរលាយនៅសីតុណ្ហភាព$-118$°C និងពុះនៅ $-108{,}1$°C ។ វាមានដង់ស៊ីតេ$5{,}9 g/l$ នៅសីតុណ្ហភាព 0°C និងសំពាធ $1 atm$ ។ វាមាន *ទំងន់អាតូមិច* 131,29 ។

**xénophile** *adj.; n.* បរទេសនិយម

**xénophilie** *n.f.* បរទេសនិយម

**xénophobe** *adj.; n.* ដែលស្អប់ជនបរទេស; ដែលស្អប់របស់មកពីបរទេស → chauvin. *Attitude xénophobe. Les racistes et les xénophobes.*

**xénophobie** *n.f.* ការស្អប់ជនបរទេស → chauvinisme. *« Une vague de xénophobie souleva la France »* (Beauvoir).

**xérophile** *adj.* ដែលធន់នឹងសំងួត។ *Plantes xérophiles.*

**xérophtalmie** *n.f.* សេរ៉ុបតាល់មី (ជំងឺស្ងួតនិងស្វិតស្បែកត្របកភ្នែកក្នុង ដែលបណ្តាលអោយងងឹតភ្នែក)

**xérophyte** *adj.* ដែលធន់នឹងសំងួត។ *Plantes xérophiles.*

**xylographe** *n.* ជាងឆ្លាក់ឈើ

**xylographie** *n.f.* សិល្បៈឆ្លាក់ឈើ។ ចំលាក់ដោយប្រើបច្ចេកទេសនេះ។ > *adj.* xylographique

**xylophage** *adj.* ដែលស៊ីឈើ. *Insecte xylophage.*។ *n.m.* សត្វល្អិតស៊ីឈើ(បាណកសត្វ)។

**xylophone** *n.m.* រនាត (មើលផងដែរ → balafon, marimba, vibraphone)

**xylophoniste** *n.* អ្នកលេងរនាត